# ៩.រឿង ចចកនិងអណ្តើក

ក្នុងសម័យព្រេងនាយ មាននិទានមួយដំណាលថាៈ ថ្ងៃមួយមានសត្វចចកនិងអណ្តើកបានជួបគ្នា ហើយបបួលគ្នាប្រលងប្រជែងដោយលោតចម្ងាយ ឆ្លងពីមាត់ស្ទឹងម្ខាងទៅមាត់ស្ទឹងម្ខាង ។ អណ្តើកបានសួរទៅឆ្កែចចកថា " នែ ! បងចចកខ្ញុំចង់ភ្នាល់ណាស់ ថ្វីបើជើងខ្ញុំខ្លី ″ ។ ចចកឆ្លើយថា " មើល៍ ! បងអណ្តើក ដែលបងឯងបបួលខ្ញុំភ្នាល់នេះ តើភ្នាល់របៀបណា ? ” ។ អណ្តើកថា "ភ្នាល់លោតឆ្លងស្ទឹងនេះ ហើយចង្អុលទៅស្ទឹងដែលនៅក្បែរខ្លួន ″ ។ ចចកថា " យី ! ខ្ញុំដូចជាឆ្ងល់ដែរ ចុះបងឯងបបួលខ្ញុំភ្នាល់ដូចម្តេច បើជើងបងឯងប្រវែងជើងក្អាត់ដូច្នេះ, លោតម្តេចនឹងកើត ″ ។ អណ្តើកឆ្លើយថា " យើ ! បងចចក មើលងាយខ្ញុំជើងខ្លីទេតើ ? បងឯងមិនទាន់ដឹងអាជើងខ្លីហ្នឹងទេ មើលបងឯងសាកល្បងមើល ! ” ។ ចចកថា " បើបងអណ្តើកឯងចាញ់ខ្ញុំ តើបានអ្វីឲ្យខ្ញុំ ! ” ។ អណ្តើកថា " ខ្ញុំសុខចិត្តរកសត្វជើងពីរ ឲ្យបងចចកឯងស៊ី″ ។ ចចកថា "បើខ្ញុំលោតចាញ់បងអណ្តើកឯង ខ្ញុំរកសត្វជើងមួយឲ្យបងឯងស៊ីជាអាហារ″ ។ ថាដូច្នោះហើយ សត្វទាំងពីរក៏ប្រុងប្រៀបរៀបចំលោតប្រឡងគ្នា ។ អណ្តើកថា " ហ៎ ! បងចចកឯងមកឈរពីមុខខ្ញុំរៀបចំលោត ″ ។ ចចកថា " ហ្អោះ ! មិនបាច់តទីឲ្យខ្ញុំទេ ″ ។ អណ្តើកមកឈរពីខាងក្រោយចចក ៗ ប្រុងនឹងបោះពួយយ៉ាងអង់អាច ។ រៀបនឹងលោត អណ្តើកក៏ខាំចុងកន្ទុយចចកជាប់ ចចកភ្ញាក់ក៏រលាស់កន្ទុយទៅ ដូចជាគេបោះអណ្តើកទៅខាងត្រើយម្ខាង ចចកធ្លាក់ទឹកប្រូង ។ អណ្តើកងើបឡើងសើច ហោះ ! ហោះ ! ហោះ ថា " យីបងចចកជើងវែង ម្តេចក៏លោតមិនរួច ″ ។ ចចកក៏ប្រវេប្រវាឡើង ទៅលើគោករលាស់ខ្លួនភឹល នឹកខឹងណាស់ក៏ចាប់លោតម្តងទៀតគម្រប់ ២ ដង ៣ ដង ក៏នៅតែចាញ់កលអណ្តើកគ្រប់លើកទាំងអស់ ។ ឯចចកបានជាហ៊ានធានារកសត្វជើង ១ ឲ្យអណ្តើកស៊ី ក្នុងពេលដែលខ្លួនចាញ់នោះ ដោយអាងថា អណ្តើកលោតមិនឈ្នះខ្លួន លុះដល់ពេលលោត ត្រឡប់ជាចាញ់អណ្តើកវិញនោះ ក៏នឹកភ័យ មិនដឹងជាទៅរកសត្វជើង ១ ឯណាឲ្យអណ្តើកស៊ី ក៏គេចរត់ភៀសខ្លួនចេញ ។ អណ្តើកក៏ខំដើរតាមរកចចក ៗ រត់ទៅ ៗ បានជួបនឹងសុភាទន្សាយ កំពុងតែធ្វើជាងដំដែកព្រឹប៉ុក ៗ បានឃើញឆ្កែចចក បោលចូលមកក៏សួរថា "បងចចកឯងមាន ភ័យអាសន្នអ្វី បានជារត់មកត្រហេបត្រហាបយ៉ាងនេះ? ” ។ ចចកឆ្លើយថា " ខ្ញុំភ័យខ្លាចសត្វអណ្តើកវាដេញតាមខាំខ្ញុំ ពីព្រោះខ្ញុំភ្នាល់លោតទឹកចាញ់វា ″ ។ សុភាទន្សាយឆ្លើយថា " អូ ! អីចឹងទេឬ ? បើដូច្នេះចូរបងកុំភ័យឲ្យសោះ ជួយដំដែកឲ្យខ្ញុំ ខ្ញុំនឹងជួយឲ្យបងឯងរួចខ្លួន″ ។ ឆ្កែចចកក៏ខំដំដែកឲ្យបងសុភាទន្សាយទៅ ។ ឯអណ្តើកក៏វារខ្វះ ៗ តាមមកទាន់ ឃើញចចកកំពុងតែដំដែក អណ្តើកក៏ស្រែកថា "យើ ! បងចចកឯងនៅទីនេះទេ ? ខ្ញុំខំតែដើររកមុខយូរហើយ ឥឡូវស្រាប់តែឃើញបងចចកមុខក្រាស់នៅទីនេះសោះ″ ។ ទន្សាយថា "ឈប់ ៗ បងអណ្តើក″ ហើយស្ទុះលោតទៅជិះលើខ្នងអណ្តើក អង្គុយប្រហោងដាក់ពង ៣ ប្របេះមាត់អណ្តើក ៗក៏លូនក្បាលចេញមកខាំពង៣ ទន្សាយដាច់មួយកំណាត់ទៅ ។ ទន្សាយដឹងថាអណ្តើកខាំពងរបស់ខ្លួនដាច់ហើយ ក៏លោតហាក់រត់ភឹង យ៉ាងលឿនអស្ចារ្យ ប្រៀបបាននឹងព្រួញ ។ ចចកបានឃើញទន្សាយរត់ដូច្នោះ ក៏ផាយត្រង់កន្ទុយភ្លឹងតាមក្រោយទន្សាយទៅដែរ ដោយនឹកស្មានថា ប្រហែលជាទន្សាយទប់ទល់នឹងអណ្តើកមិនឈ្នះ ។ អណ្តើកស្រែកឃាត់ថា " ឈប់ ៗ ! ” ។ ចចកឆ្លើយថា " ទេ ! អញមិនឈប់ទេ អញមិតចូលព្រៃជាមួយបងទន្សាយហើយ ″ ។

ថាតែប៉ុណ្ណោះ ចចករត់ឥតងាកក្រោយតម្រង់ទៅព្រៃបាត់ទៅលែងចូលមកភូមិស្រុកវិញរហូត ។

ព្រោះមានរឿងដំណាលដូច្នេះ បានជាអ្នកប្រាជ្ញបុរាណ លោកបានក្រើនរំលឹកថា " អ្នកធំកុំមើលងាយអ្នកតូចតាច ប្រយ័ត្នមានគ្រោះថ្នាក់ដូចរឿងដំណាលមកនេះ " ។